# ព្រះរាជក្រឹត្យ
# ស្តីពី
# ការបង្កើតអជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
# ហៅថាអាជ្ញាធរ "អប្សរា"

នស/រកត/០២៩៥/១២

## ព្រះរាជក្រឹត្យ

## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
## ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២ នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីសម្រេចលេខ២៥ សសរ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៣ នៃរាជរដ្ឋាភិបាលបណ្តោះអាសន្នកម្ពុជា ស្តីអំពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីអំពីការរៀបចំតំបន់ និងការគ្រប់គ្រងតំបន់សៀមរាបអង្គរ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរោបនីយកម្ម និងសំណង់ និងដោយគណៈរដ្ឋមន្ត្រីបានយល់ព្រមផង តាមរយៈការប្រជុំពេញអង្គថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៥។

## ត្រាស់បង្គាប់
## ជំពូកទី១
## បទបញ្ញត្តិទូទៅ

មាត្រា១ :

ត្រូវបានបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អប្សរា" ដែលជាគ្រឹះស្ថានសាធារណៈមួយ ប្រកបដោយបុគ្គលភាពគតិយុត្តិ មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ។

មាត្រា២ :

អាជ្ញាធរ "អប្សរា" មានបេសសកម្មគិតគូរ ដឹកនាំការងាររៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍ នៃតំបន់ចំនួនប្រាំ ដែលកំណត់នៅក្នុង ព្រះរាជក្រឹត្យលេខ០០១ នស ចុះថ្ងៃ២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីអំពីការកំណត់ និងការចាត់ចែងតំបន់សៀមរាបអង្គរ ។ ដើម្បីសម្រេចទិសដៅនេះ អាជ្ញាធរ "អប្សរា" ព្រមជាមួយក្រសួងពាក់ព័ន្ធត្រូវធ្វើជាអាណាព្យាបាលរួម លើគ្រឹះស្ថានទាំឡាយ ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងរមណីយដ្ឋានទាំងនោះ សរុបមាន ៖

- អភិរក្សដ្ឋានអង្គរ ដែលមានបេសកម្មថែរក្សា រៀបចំ និងជួសជុលរមណីយដ្ឋានអង្គរដោយ ធ្វើសហាការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។
- ភ្នាក់ងាររៀបចំការអភិវឌ្ឍន៍ទេសចរណ៍អង្គរ ដែលទទួលបន្ទុកអភិវឌ្ឍន៍ និងសម្របសម្រួលបណ្តាញទេសចរណ៍ក្នុង តំបន់នេះ ដោយធ្វើសហាការជាមួយក្រសួងបរិដ្ឋាន ក្រសួងទេសចរណ៍ និងជាមួយអនុគណៈកម្មាធិការខេត្ត រៀបចំទឹកដី នគរោបនីយកម្ម និងសំណង់។
- ភ្នាក់ងារអភិវឌ្ឍន៍នគរោបនីយកម្ម ទទួលបន្ទុកគិតគូរ និងធ្វើឲបានសម្រេចនូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងឧបរិចនា សម្ព័ន្ធផ្នែកទេសចរណ៍ក្នុងតំបន់នេះ ក្រោមការក្តោបក្តាប់ផ្ទាល់របស់អាជ្ញាធរ "អប្សរា" សហាការជាមួយអភិបាលខេត្តសៀមរាប និងអនុគណៈកម្មាធិការខេត្តរៀបចំទឹកដីនគរោបនីយកម្ម និងសំណង់។
- វិទ្យាស្ថានវប្បធម៌ខ្មែរដែលទទួលបន្ទុកបណ្តុះបណ្តាលប្រវត្តិវិទូ បុរាណវត្ថុវិទូ និងភ្នាក់ងារអភិរក្សទទួលបន្ទុកគ្រប់គ្រង និងទ្រទ្រង់រមណីយដ្ឋានអង្គរ ហើយនឹងរ៉ាប់រងបង្កើនចំណេះដឹងទាំងឡាយនៅក្នុងផ្នែកវប្បធម៌ និងអរិយធម៌ខ្មែរ ដោយសហ- ការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ស្នងការពិសេសការពារបេតិកភណ្ឌនៃក្រសួងមហាផ្ទៃ អនុវត្តភារកិច្ចរបស់ខ្លួន ក្នុងតំបន់អង្គរ ដោយសហាការជាមួយអាជ្ញាធរ ខេត្តសៀមរាប។

បណ្តាគ្រឹះស្ថានខាងលើនេះ នឹងត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។

មាត្រា៣ :

ដើម្បីសម្រេចនូវបេសកកម្មរបស់ខ្លួន អាជ្ញាធរ "អប្សរា" ត្រូវកំណត់ឱ្យមានសៀវភៅបន្ទុកសម្រាប់អង្គការនានាដែលពាក់ព័ន្ធ ដល់ការគ្រប់គ្រងរមណីយដ្ឋាន និងការរៀបចំតំបន់អង្គរ ។ ក្នុងន័យនេះអាជ្ញាធរ " អប្សរា" អាច ៖

- ចុះកិច្ចសន្យា អំពីកម្មវិធីប្រចាំឆ្នាំជាមួយអង្គការទាំងនោះ ។
- ចុះកិច្ចសន្យាជាមួយអាជ្ញាធរខេត្ត ដែលមានបំណងធ្វើការរៀបចំនគរោបនីយកម្ម ការអភិវឌ្ឍន៍ជនបទ និងការផ្តល់សេវា ផ្សេងៗ ជាយថាហេតុ ។
- សហាការជាមួយគ្រប់វិទ្យាស្ថាន គ្រប់អង្គការផ្សេងៗ គ្រប់មូលនិធិ និងសមាគមខ្មែរ បរទេស និងអន្តរជាតិដែលដើរតាម ទិសដៅ ឆ្លើយតបនឹងសមត្ថកិច្ចអាជ្ញាធរ "អប្សរា" ។
- សហាការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងរឿងវិនិយោគគ្រប់ប្រភេទណា ដែលមានការពាក់ព័ន្ធជាមួយបេសកកម្ម

របស់អាជ្ញាធរ "អប្សរា"។

- ប្រគល់សិទ្ធិធ្វើសកម្មភាពផ្សេងៗ ឬចេញច្បាប់អនុញ្ញាតកាន់កាប់ ផ្តល់ការជួលដីរដ្ឋឱ្យអ្នកវិនិយោគ ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់អាជ្ញាធរ "អប្សរា" ។

អាស្រ័យតាមកម្រិតនៃការរីកចំរើននូវសកម្មភាពរបស់ខ្លួន អាជ្ញាធរ "អប្សរា" អាចប្រគល់សិទ្ធិទាំងស្រុង ឬមួយភាគដែលរៀបរាប់ខាងលើនេះ ជូនដល់គ្រឹះស្ថានដែលមានចែងក្នុងមាត្រា២ ។

ក្នុងរយៈពេលរង់ចាំការបង្កើតគ្រឹះស្ថានទាំងឡាយ ដូចបានព្រាងទុកក្នុងមាត្រា២ ខាងលើ អាជ្ញាធរ "អប្សរា" ទទួលរ៉ាប់រងរាល់បេសកកម្មដែលជាសមត្ថកិច្ចរបស់គ្រឹះស្ថាននោះ ។

មាត្រា៤ :
អាជ្ញាធរ "អប្សរា" ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីនយោបាយសកម្មភាពរបស់ខ្លួន ការវិនិយោគ និងសេចក្តីអនុញ្ញាតផ្សេងៗដែលត្រូវបានសម្រេចហើយ ។

## ជំពូកទី២
## រដ្ឋបាល

មាត្រា៥ :
អាជ្ញាធរ "អប្សរា" ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាព ៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីទី១ | ជាសហប្រធាន |
| - នាយករដ្ឋមន្ត្រីទី២ | ជាសហប្រធាន |
| - ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ឬតំណាង | ជាអនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬតំណាង | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន ឬតំណាង | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬតំណាង | សមាជិក |
| - អភិបាលខេត្តសៀមរាប ឬតំណាង | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១រូប ឬតំណាង | សមាជិក |

មាត្រា៦:

ក្រុមប្រឹក្សាភិបាលមានសិទ្ធិអនុម័ត ៖

- ការតំរង់ទិសរាល់សកម្មភាពរបស់អាជ្ញាធរ "អប្សរា"
- បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរ "អប្សរា"
- របាយការណ៍ប្រចាំឆ្នាំដែលអគ្គនាយកបានដាក់ជូន
- ចំនួនទឹកប្រាក់ និងថ្លៃឈ្នួលផ្សេងៗ និងចំណូលគ្រប់បែបដែលអាជ្ញាធរ "អប្សរា"ប្រមូលទាមទារ
- ចំនួនទឹកប្រាក់ ហើយនិងលក្ខខ័ណ្ឌនៃការខ្ចីបុល
- រាល់បញ្ហាដែលសហប្រធាន និងអគ្គនាយកដាក់ឲពិនិត្យ។

មាត្រា៧:

ក្រុមប្រឹក្សាភិបាលរួមប្រជុំយ៉ាងតិច ៦ដងក្នុងមួយឆ្នាំ តាមរយៈការកោះអញ្ជើញរបស់សហប្រធាន ដែលជាអ្នកកំណត់របៀប វារៈ។ ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំក្នុងខែបន្ទាប់ បើសិនជាការកោះអញ្ជើញត្រូវបានសុំដោយសមាជិកចំនួន ១ភាគ៤ នៃសមាជិកទាំងអស់ ។ ការអនុម័តផ្សេងៗត្រូវកំណត់យកតាមសម្លេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ ក្នុងករណីមានចំណែកសម្លេងស្មើគ្នា សម្លេងសហប្រធានមានឧត្តមានុភាព ។

សហប្រធានអាចអញ្ជើញរាល់បុគ្គលណាក៏ដោយ ឱ្យមកចូលរួមបានក្នុងអង្គប្រជុំ ក្នុងករណីដែលខ្លួនយល់ថា វត្តមានបុគ្គលនោះមានផលប្រយោជន៍។

មាត្រា៨ :

អាជ្ញាធរ "អប្សរា" មានទីចាត់ការទូទៅ និងនាយកដ្ឋានជំនាញចំនួន៣ ទៀតគឺ នាយកដ្ឋានសកម្មភាពភូមិបាល នាយកដ្ឋាននគរោបនីយកម្ម និងនាយកដ្ឋានហិរញ្ញកិច្ចនិងគណនេយ្យ ។

ទីចាត់ការទូទៅដឹកនាំដោយអគ្គនាយកមួយរូប និងមានអ្នកជំនួយការជាទីប្រឹក្សា មួយរូបផ្នែកខាងរៀបចំផែនការ ហើយនិងការងារចាត់តាំង។

នាយកដ្ឋានកិច្ចការភូមិបាលមានតួនាទី ត្រួតពិនិត្យសកម្មភាពភូមិបាល ។ នាយកដ្ឋាននេះដឹកនាំដោយអ្នកឯកទេសខាងភូមិបាលមួយរូប។

នាយកដ្ឋានកិច្ចការនគរោបនីយកម្ម (នា.ក.ន) មានភារកិច្ច ៖

- ទទួលខុសត្រូវក្នុងការបន្តកិច្ចការ និងការអនុវត្តន៍ជាក់ស្តែងនូវគម្រោងអភិវឌ្ឍន៍ទាំងឡាយ ក្នុងតំបន់។
- ទទួលខុសត្រូវការសិក្សាស្រាវជ្រាវផ្នែកនគរោបនីយកម្ម ដើម្បីឱ្យមានការ អនុវត្តន៍ព្រមទាំងគោរពរាល់បញ្ញត្តិ ក្នុងកិច្ចការទាំងនេះ ។ នា.ក.ន ដឹកនាំដោយស្ថាបត្យករនគរោបនីយកម្មមួយរូប ។
- នាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យទទួលខុសត្រូវកិច្ចការកាន់កាប់គណនេយ្យរបស់អាជ្ញាធរ "អប្សរា" ។ នាយកដ្ឋាននេះជាជំនួយការដល់អគ្គនាយក ក្នុងកិច្ចការត្រួតពិនិត្យឱ្យបានត្រឹមត្រូវនូវរាល់សកម្មភាពពាក់ព័ន្ធកិច្ចសន្យា ការងារវិនិយោគ ឬការអនុញ្ញាត ។

នាយកដ្ឋាននេះដឹកនាំដោយនាយកហិរញ្ញកិច្ច និងគណនេយ្យមួយរូប ដែលអាចចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ដោយមានសម្លេងត្រឹមតែជាការផ្តល់យោបល់ ។

មាត្រា៩ :

អគ្គនាយកនៃអាជ្ញាធរ "អប្សរា" ត្រូវតែងតាំងដោយអនុក្រឹត្យ តាមការស្នើរបស់ ក្រុមប្រឹក្សាភិបាលសម្រាប់រយៈពេល ៣ ឆ្នាំ រួចអាចបន្ត ៣ ឆ្នាំម្តងៗ ទៀតបាន ។ អគ្គនាយកជាអាណាប័ក ក្នុងការចំណាយរបស់អជ្ញាធរ "អប្សរា" ។

អគ្គនាយកទទួលរ៉ាប់រងអនុវត្ត រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ហើយនិងចាត់វិធានការគ្រប់គ្រង គ្រប់បែបយ៉ាង ក្នុងដំណើរការរបស់អាជ្ញាធរ "អប្សរា" ។

អគ្គនាយកតំណាងឱ្យអាជ្ញាធរ "អប្សរា" នៅចំពោះមុខតុលាការ ។ អគ្គនាយកតែងតាំង និងតម្លើងឋានន្តរសក្តិបុគ្គលិក បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។

អគ្គនាយកមានអំណាចពេញទីលើបុគ្គលិកអាជ្ញាធរ "អប្សរា" លើកលែងតែនាយកហិរញ្ញកិច្ច និងគណនេយ្យ ។

មាត្រា១០ :

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ "អប្សរា" ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៣
## វិសមិតភាព

មាត្រា១១ :

អគ្គនាយក នាយកហិរញ្ញកិច្ច និងគណនេយ្យ សមាជិកទាំងអស់នៃក្រុមប្រឹក្សាភិបាល របស់អាជ្ញាធរ "អប្សរា" ពុំអាចទទួលផលប្រយោជន៍អ្វី ដោយផ្ទាល់ក្តី ឬតាមរយៈស្វាមី ឬភរិយា ឬកូនរបស់ខ្លួននៅក្នុងសហគ្រាសឯកជនណាមួយ ដែលធ្វើអាជីវកម្មក្រោមសមត្ថកិច្ចអាជ្ញាធរ "អប្សរា"។

ក្នុងករណីមិនគោរពកាតព្វកិច្ចនេះ ក្រុមប្រឹក្សាភិបាលត្រូវធ្វើកំណត់ហេតុ ស្តីពីវិសមិតភាពការងាររបស់សាមីជន ហើយប្រកាសឱ្យលាលែងពីមុខតំណែងតែម្តង ។

## ជំពូកទី៤
## ប្រភពធនធាន

មាត្រា១២ :

ធនធានរបស់អាជ្ញាធរ "អប្សរា" មាន ៖

- វិភាគទានពីរដ្ឋ និងពីឃុំ ស្រុក ខេត្តនានា
- អំណោយមរតក និងវិភាគទានអន្តរជាតិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ "អប្សរា" ។
- ចំណូលបានមកពីសកម្មភាពផ្ទាល់របស់អាជ្ញាធរ "អប្សរា" ដូចជាបំណុលថ្លៃឈ្នួលបានមកពីការចេញច្បាប់កាន់កាប់ផ្សេងៗ។
- ប្រាក់កម្រៃបានមកពីប្រភពសេវាកម្មផ្សេងៗ ផ្តល់មកពីអង្គការសាធារណៈ ឬឯកជន ។

- ប្រាក់ខ្ចីបុល ដែលធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ "អប្សរា" ។

អាជ្ញាធរ "អប្សរា" អាចទទួលយកនូវទ្រព្យចលនវត្ថុ អចលនវត្ថុ ឬដីធ្លីដែលគេប្រគល់ឱ្យ ។

មាត្រា១៣ :

គម្រោងចំណូល និងចំណាយ សម្រាប់ឆ្នាំបន្ទាប់ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយ៉ាងយូរបំផុត នៅថ្ងៃទី ០១ ខែធ្នូ។

## ជំពូកទី៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យគណនេយ្យ

មាត្រា១៤ :

ការគ្រប់គ្រងហិរញ្ញវត្ថុនៃអាជ្ញាធរ "អប្សរា" ជាភារកិច្ចរបស់នាយកហិរញ្ញកិច្ច និងគណនេយ្យ ១រូបដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីរូបនេះ ដែលជាអ្នកទទួលខុសត្រូវ ក្នុងការគ្រប់គ្រងមូលនិធិនេះ ព្រមទាំងជាអ្នកកាន់កាប់បញ្ជីសារពើភ័ណ្ឌបេតិកភណ្ឌរបស់អជ្ញាធរ "អប្សរា" ត្រូវធ្វើសម្បថមុន នឹងចូលកាន់តំណែង ។

មាត្រា១៥ :

ការត្រួតពិនិត្យគណនេយ្យ ត្រូវប្រគល់ឱ្យស្នងការគណនេយ្យ ១រូប ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ស្នងការគណនេយ្យទទួលអំណាចផ្ទៀងផ្ទាត់បញ្ជីបេឡា ត្រួតពិនិត្យភាពប្រក្រតីនៃគុលុ្យការផ្សេងៗ ព្រមទាំងភាពត្រឹមត្រូវនៃគណនេយ្យ ។ ស្នងការគណនេយ្យអាចធ្វើការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យរាល់ពេលដែលខ្លួនយល់ថាចាំបាច់ ។

រាល់ពេលប្រជុំក្រុមប្រឹក្សាភិបាល ស្នងការគណនេយ្យធ្វើរបាយការណ៍អំពីការដែលខ្លួនបានធ្វើកន្លងមក ។ ប្រសិនបើខ្លួនសង្កេតឃើញភាពមិនប្រក្រតី និងមិនទៀងទាត់ ស្នងការគណនេយ្យត្រូវជំរាបអង្គប្រជុំ ព្រមទាំងបញ្ចេញយោបល់លើស្ថានភាពហិរញ្ញវត្ថុនោះ ។

បើមានករណីបន្ទាន់ ស្នងការគណនេយ្យអាចសុំសហប្រធានក្រុមប្រឹក្សាភិបាលឱ្យកោះអញ្ជើញប្រជុំក្រុមប្រឹក្សាភិបាល ។ ស្នងការគណនេយ្យមានសិទ្ធិទទួលកម្រៃក្នុងកម្រិត ដែលក្រុមប្រឹក្សាភិបាលបានកំណត់ ។ ក្រោយពីបានត្រួតពិនិត្យគណនេយ្យប្រចាំឆ្នាំរួច ហើយបើស្នងការគណនេយ្យពុំឃើញមានភាពមិនប្រក្រតី ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុទេនោះ ស្នងការគណនេយ្យត្រូវប្រគល់មុញ្ចនកិច្ចដល់ក្រុមប្រឹក្សាភិបាល អគ្គនាយក និងនាយកហិរញ្ញកិច្ចគណនេយ្យនៃអាជ្ញាធរ "អប្សរា" ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

មាត្រា១៦ :

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១៧ :

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរោបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាបត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា១៨ :

ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៥
ព្រះហស្តលេខា

**នរោត្តម សីហនុ**

ត្រឡប់ទៅលើ